# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨៩៤
ចុះថ្ងៃទី២៤-កក្កដា-២០២០
សំណុំរឿងជំនុំជម្រះលេខ ១៧៦៤
ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០
សាលក្រមព្រហ្មទណ្ឌលេខ: **១០០"ឆ"**
ចុះថ្ងៃទី២៥-ធ្នូ-២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណ:នៅសាលាដំបូងខេត្តសៀមរាប។
-កាលបរិច្ឆេទបើកសវនាការថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង៨និង ០០ នាទីព្រឹក ។
-កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ៩ និង ០០នាទីព្រឹក។
ដោយមានសមាសភាពជំនុំជម្រះដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រម

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៨៩៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] **ឧុទ្ធី** ភេទប្រុស អាយុ ៦៤ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិ [redacted] រាជធានីភ្នំពេញ មានទីលំនៅមុនពេលចាប់ខ្លួនភូមិខ្នារក្រៅ ឃុំកន្ទួត ស្រុកស្វាយលើខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរកសិករ កម្រិតវប្បធម៌ថ្នាក់ទី៦ ប្រពន្ធឈ្មោះ [redacted] ស្រីមុំ ឪពុកឈ្មោះ [redacted] សេក "ស" ម្ដាយឈ្មោះ [redacted] កុន "ស" ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការគ្មាន។ (ក្នុងឃុំ)

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ៩៣២ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០។

២. ឈ្មោះ [redacted] **ណាត** ភេទប្រុស អាយុ ៥៨ឆ្នាំ ជនជាតិខ្មែរ កើតនៅភូ [redacted] ខេត្តស្វាយរៀង មានទីលំនៅមុនពេលចាប់ខ្លួនភូមិជប់វំដេង ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរកសិករ កម្រិតវប្បធម៌ថ្នាក់ទី៧ ប្រពន្ធឈ្មោះ [redacted] ចេង មានកូនចំនួន ៥នាក់ ឪពុកឈ្មោះ [redacted] ភិន "ស" ម្ដាយឈ្មោះ [redacted] អែម "ស" ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការគ្មាន។ (ក្នុងឃុំ)



Scanned with CamScanner

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ ៩៣៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០។

៣. ឈ្មោះ [redacted] **សុខុម** ភេទប្រុស អាយុ ៦៤ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិ [redacted] ខេត្តតាកែវ មានទីលំនៅមុនពេលចាប់ខ្លួនភូមិជប់រំដេង ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរកសិករ កម្រិតវប្បធម៌ថ្នាក់ទី៦ចាស់ ប្រពន្ធឈ្មោះ [redacted] ឃុន ឪពុកឈ្មោះ [redacted] ញឹម "ស" ម្តាយឈ្មោះ [redacted] សុខុម "ស" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។ (ក្នុងឃុំ)

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ ៩៣៣ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០។

៤. ឈ្មោះ [redacted] **វុទ្ធី ឬ** [redacted] **វុទ្ធ** ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិ [redacted] ខេត្តសៀមរាប មុខរបរជានាយទាហានឈរជើងនៅទីបញ្ជាការទិសកងទ័ពជើងគោក ស្ថិតនៅចំណុចខ្នារផ្តៅល ក្នុងភូមិស្រែពរ ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប។ (គេចខ្លួន)

ដីកាបង្គាប់ឲ្យនាំខ្លួនលេខៈ៦៩៧ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០។

ជាប់ចោទពីបទៈ **ឆបោក** ប្រព្រឹត្តនៅភូមិសែនជ័យ និងភូមិជប់រំដេង ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

- លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វុទ្ធី, [redacted] ណាត , [redacted] សុខុម ។

- លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ឬ កឹម វុទ្ធ ។

- **បានឃើញ** របាយការណ៍សំយោគ លេខៈ ០៧ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលស្រុកស្វាយលើ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប។

- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១៧៦៧ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។

- **បានឃើញ** ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ៨៩៩៥ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៣៣៩៧ ពស.ព្រជ (ក) ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## <u>ដំណើររឿងហេតុមានដូចតទៅ</u>

កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ឈ្មោះ [redacted] ស៊ីនួន បានទំនាក់ទំនងឈ្មោះ [redacted] វុទ្ធី ទៅមើលដីនៅចំណុចភូមិរំចេក១ ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ពេលទៅដល់ឈ្មោះ [redacted] ស៊ីនួន បានប្រាប់ទៅឈ្មោះ [redacted] វុទ្ធី ថាដីនោះមានទំហំ ២ ០០០(ពីរពាន់)ហិចតា គាត់រកលក់តែមិនដឹងរត់ការស៊ីញ៉េប្លង់តាមណា ឮដូចនោះឈ្មោះ [redacted] វុទ្ធី ក៏ប្រាប់ថាគាត់ស្គាល់ឯកឧត្តមម្នាក់ឈ្មោះ [redacted] វុទ្ធី ជាទាហានឈរជើងនៅទិសបញ្ជាការកងទ័ពជើងគោក។ ក្រោយមកឈ្មោះ [redacted] ស៊ីនួន និងឈ្មោះ [redacted] វុទ្ធី បានណាត់ឈ្មោះ [redacted] វុទ្ធី ទៅជួបនៅផ្ទះរបស់ឈ្មោះ [redacted] ស៊ីនួន ហើយបាននិយាយគ្នាព្រមព្រៀងឲ្យដីទៅ



Scanned with CamScanner

ឈ្មោះ [redacted] វុទ្ធី ដែលមានក្បាលដីប្រវែង ៦០០ម៉ែត្រ។ បន្ទាប់មកឈ្មោះ [redacted] ស៊ីនួន ឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] វុទ្ធី បានពិភាក្សាគ្នាថាបើលក់ទាំងអស់គ្មានអ្នកណាមានលុយទិញទេ ប៉ុន្តែបើពុះជាដីឡូត៍លក់ទើបគេមានលុយទិញ។ ក្រោយពីពិភាក្សាគ្នារួចបានប្រហែលជា ២ ឬ៣ថ្ងៃ ស្រាប់តែឈ្មោះ [redacted] ស៊ីនួនបានស្លាប់បាត់ទៅ។ ក្រោយមកទៀតឈ្មោះ [redacted] វុទ្ធី ក៏បានឱ្យឈ្មោះ [redacted] វុទ្ធី រៀបចំចុះឈ្មោះប្រជាពលរដ្ឋដែលចង់ទិញដីឡូត៍ និងប្រមូលប្រាក់ក្នុងមួយឡូត៍ ៥០ ០០០ (ប្រាំម៉ឺន)រៀល ដើម្បីរត់ការកាត់ប្លង់ហើយឈ្មោះ [redacted] វុទ្ធី ត្រូវការប្រាក់ចំនួន ១ ០០០ ០០០ (មួយលាន) រៀល មុន។ ឮដូចនេះឈ្មោះ [redacted] វុទ្ធី ក៏បានទៅបបួលបក្ខពួកចំនួនពីរនាក់ទៀតឈ្មោះ [redacted] ណាត និងឈ្មោះ [redacted] សុខុម ដើម្បីគៀងគប្រជាពលរដ្ឋឱ្យចុះឈ្មោះទិញដីឡូត៍ និងប្រមូលប្រាក់រត់ការ។នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ស្ថិតនៅភូមិសែនជ័យ និងភូមិដប់រំដេង ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប ឈ្មោះ [redacted] វុទ្ធី បានចុះឈ្មោះប្រជាពលរដ្ឋបានចំនួន ០៧នាក់ ប្រមូលប្រាក់បានចំនួន ៣៥០ ០០០(សាមសិបប្រាំម៉ឺន)រៀល ឈ្មោះ [redacted] ណាត ចុះឈ្មោះប្រជាពលរដ្ឋបានចំនួន ៥៨ នាក់ ប្រមូលប្រាក់បានចំនួន ១៥០ ០០០(ដប់ប្រាំម៉ឺន) រៀល និងឈ្មោះ [redacted] សុខុម ចុះឈ្មោះប្រជាពលរដ្ឋបានចំនួន ១៩នាក់ ប្រមូលប្រាក់បានចំនួន ៦៥០ ០០០ (ហុកសិបប្រាំម៉ឺន) រៀល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានឆ្លើយថាៈ កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ឈ្មោះ [redacted] ស៊ីនួន ដែលជាក្មេីរបស់ខ្លួនបានមកនិយាយប្រាប់ខ្លួនថាគាត់មានដីចំនួន១០០០ (មួយពាន់) ហិចតា ហើយគាត់ចង់ធ្វើប្លង់កាន់កាប់ស្របច្បាប់រួចហើយលក់ចេញ ប៉ុន្តែគាត់មិនដឹងរត់ការតាមអ្នកណាពេលនោះខ្លួនក៏បានណែនាំឱ្យទៅពឹងឯកឧត្តមឈ្មោះ [redacted] វុទ្ធី ជាទាហានដើម្បីជួយរត់ការធ្វើប្លង់ឱ្យ។ ពេលដែលបានជួបនិយាយជាមួយឯកឧត្តម [redacted] វុទ្ធី ពេលនោះឈ្មោះ [redacted] វុទ្ធី បានសុំចំណែកដីពីឈ្មោះ [redacted] ស៊ីនួន ចំនួនពាក់កណ្តាលជាថ្នូនឹងការរត់ការធ្វើប្លង់កាន់កាប់ ពេលនោះឈ្មោះ [redacted] ស៊ីនួន ក៏បានយល់ព្រមឱ្យដីទៅឈ្មោះ [redacted] វុទ្ធី ក្បាលចំនួន ៦០០ម៉ែត្រ បណ្តោយមិនដឹងប៉ុន្មាននោះទេ។ បន្ទាប់មកឈ្មោះ [redacted] ស៊ីនួន ឈ្មោះ [redacted] វុទ្ធី និងខ្លួនបានពិភាក្សាគ្នាថាបើលក់ទាំងអស់គ្មានអ្នកណាមានលុយទិញទេ ប៉ុន្តែបើពុះជាដីឡូត៍លក់ទើបគេមានលុយទិញ។ ក្រោយពីពិភាក្សាគ្នារួចបានប្រហែលជា ២ ឬ៣ថ្ងៃ ស្រាប់តែឈ្មោះ [redacted] ស៊ីនួន បានស្លាប់បាត់ទៅ។ បន្ទាប់មកទៀតឈ្មោះ គីម វុទ្ធី បានឱ្យខ្លួនរៀបចំចុះឈ្មោះប្រជាពលរដ្ឋដែលស្ម័គ្រចិត្តទិញដីឡូត៍ ដែលមានទំហំ ៥០ ម៉ែត្រ គុណ ៤០០ ម៉ែត្រ ក្នុងតម្លៃ ៣០០(បីរយ) ដុល្លារអាមេរិកដោយការចុះឈ្មោះនោះតម្រូវឱ្យប្រជាពលរដ្ឋបង់លុយក្នុងម្នាក់ចំនួន ៥០ ០០០ (ប្រាំម៉ឺន) រៀល ដើម្បីយកលុយនេះទៅរត់ការជាមួយអាជ្ញាធរភូមិក្នុងការរៀបចំពុះជាដីឡូត៍បែងចែកឱ្យប្រជាពលរដ្ឋដែលបានចុះឈ្មោះទិញ។ លុះមកដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ខ្លួនបានយករឿងពុះដីឡូត៍លក់មកនិយាយប្រាប់ឈ្មោះ [redacted] សុខុម , ឈ្មោះ [redacted] ណាត ពេលនោះអ្នកទាំងពីរក៏បានចុះឈ្មោះទិញម្នាក់មួយឡូត៍ផងដែរ។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ខ្លួនបានពឹងឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] ណាត និងឈ្មោះ [redacted] ផល្លី ជាអ្នករស់នៅភូមិសែនជ័យឱ្យជួយចុះឈ្មោះប្រជាពលរដ្ឋ ពេលនោះដោយសារខ្លួនគ្មានលុយឱ្យថ្លៃឈ្នួលអ្នកទាំងបី ខ្លួនក៏បានគេទៅឈ្មោះ [redacted] វុទ្ធី ដើម្បីសុំដីឡូត៍ឱ្យអ្នកទាំងបីម្នាក់មួយឡូត៍ជាថ្លៃជួយចុះឈ្មោះប្រជាពលរដ្ឋ ហើយឈ្មោះ [redacted] វុទ្ធី ក៏យល់ព្រម។ ខ្លួនបានចុះឈ្មោះប្រជាពលរដ្ឋបានចំនួន ៧ គ្រួសារ បានលុយចំនួន ៣៥ ០០០(សាមសិបប្រាំម៉ឺន)រៀល ប៉ុន្តែមិនមែនខ្លួនសសេរដោយខ្លួនឯងទេ គឺ

ឈ្មោះ [redacted] ផល្លី ជាអ្នកជួយសសេរឱ្យ ហើយលុយគឺឈ្មោះ [redacted] ផល្លី ជាអ្នកកាន់ចំណែកឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] ណាត ខ្លួនមិនបានដឹងថាពួកគេចុះឈ្មោះបានម្នាក់ប៉ុន្មាននោះទេ។ ពេលកំពុងតែចុះឈ្មោះស្រាប់តែសមត្ថកិច្ចបានចុះហាមឃាត់មិនឱ្យចុះឈ្មោះតទៅទៀតខ្លាចចុះបោកគេ ហើយពួកខ្លួនក៏ឈប់ធ្វើសកម្មភាពនេះតទៅទៀត រហូតមកដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ ស្រាប់តែសមត្ថកិច្ចកោះហៅពួកខ្លួនទៅសាកសួរអធិការដ្ឋានស្រុកស្វាយលើ ហើយក៏បានឃាត់ខ្លួនពួកខ្លួនតែម្តង ។ ក្នុងការធ្វើសកម្មភាពចុះឈ្មោះប្រជាពលរដ្ឋនេះ ខ្លួនទទួលបានដីឡូត៍ចំនួនមួយឡូត៍ដូចពួកគេដែរ។ ប្រជាពលរដ្ឋដែលទៅចុះឈ្មោះមានមកពីភូមិជប់រំដេង និងភូមិសែនជ័យ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប។

-ជនជាប់ចោទឈ្មោះ [redacted] ណាត បានឆ្លើយថា៖ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ខ្លួនបានទៅតភ្លើងនៅវត្តជប់រំដេង ហើយក៏បានជួបឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] សុខុម ពេលនោះអ្នកទាំងពីរនាក់បាននិយាយប្រាប់ខ្លួនថាឯកឧត្តមឈ្មោះ [redacted] វុទ្ធី មានដីចំនួន១០០០ (មួយពាន់) ហិចតា ស្ថិតនៅភូមិរំចេក១ ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ហើយឯកឧត្តមឈ្មោះ [redacted] វុទ្ធី ចង់អភិវឌ្ឍន៍ដីតំបន់នោះ ដោយឱ្យពួកឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] សុខុម ជាអ្នកដើរចុះឈ្មោះប្រជាពលរដ្ឋណាដែលចង់ទៅរស់នៅលើដីក្នុងតំបន់នោះ ដោយការចុះឈ្មោះត្រូវបង់លុយចំនួន ៥០ ០០០(ប្រាំម៉ឺន) រៀល ជាសោហ៊ុយសម្រាប់គេនាំទៅមើលដី។ ពេលនោះខ្លួនក៏បានឱ្យឈ្មោះ [redacted] សុខុម ចុះឈ្មោះខ្លួនមួយនឹងគេដែរ ប៉ុន្តែខ្លួនមិនទាន់បានបង់លុយថ្លៃធ្វើសោហ៊ុយទៅមើលដីចំនួន ៥០ ០០០ (ប្រាំម៉ឺន) រៀល នោះទេ។ លុះដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ៧ ព្រឹក ខ្លួនបានទៅផឹកការហៅនៅផ្ទះឈ្មោះ [redacted] រឿន ស្រាប់តែបានជួបឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] សុខុម កំពុងចុះឈ្មោះប្រជាពលរដ្ឋដែលចង់ទៅមើលដី ដើម្បីទិញពេលនោះអ្នកទាំងពីរក៏បានពឹងឱ្យខ្លួនជួយចុះឈ្មោះប្រជាពលរដ្ឋឱ្យពួកគេ ហើយខ្លួនក៏បានចុះឈ្មោះប្រជាពលរដ្ឋបានចំនួន ១៩ គ្រួសារ បានលុយចំនួន ១៥០ ០០០(ដប់ប្រាំម៉ឺន)រៀល ដោយអ្នកខ្លះបង់លុយតែម្តង ចំណែកអ្នកខ្លះទៀតចាំបង់នៅពេលក្រោយ។ ពេលកំពុងចុះឈ្មោះស្រាប់តែសមត្ថកិច្ចក៏បានចុះមកដល់ហាមឃាត់មិនឱ្យចុះតទៅទៀត ពេលនោះខ្លួនក៏ឈប់ហើយដើរចេញទៅជាមួយសមត្ថកិច្ចក្រុមរបស់ខ្លួន (ខ្លួនជាប្រជាការពារភូមិ) តែម្តង។ ក្រោយមកខ្លួនបានទៅមើលដី ហើយបានជួបឯកឧត្តមឈ្មោះ [redacted] វុទ្ធី ផងដែរពេលនោះគាត់ប្រាប់ថាគាត់រកលក់ដីឱ្យប្រជាពលរដ្ឋដែលចង់ទៅរស់នៅទីនោះក្នុងតម្លៃ ៣០០ (បីរយ) ដុល្លារអាមេរិក ក្នុងទំហំ ២ (ពីរ) ហិចតា ហើយចំពោះប្រជាពលរដ្ឋដែលចុះឈ្មោះទិញដីទាំងអស់មិនតម្រូវឱ្យបង់លុយភ្លាមទេ រង់ចាំឯកឧត្តម គឹម វុទ្ធី នាំទៅមើលដីរួចសិន បើអ្នកណាចង់ទិញគាត់នឹងរត់ការផ្ទេរកម្មសិទ្ធិមកឱ្យ ប៉ុន្តែតម្រូវឱ្យបង់លុយថ្លៃរត់ការមួយចំនួនសិន នៅខ្វះលុយប៉ុន្មានចាំទទួលបានប័ណ្ណកាន់កាប់រួចហើយចាំបង់បង្គ្រប់តាមក្រោយ។ ក្រោយមកនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ សមត្ថកិច្ចខាងអធិការស្រុកស្វាយលើបានហៅខ្លួនឱ្យទៅបំភ្លឺសារជាថ្មីអំពីរឿងចុះឈ្មោះប្រជាពលរដ្ឋនោះ ពេលគេសួរនាំរួចហើយស្រាប់តែគេឃាត់ខ្លួនតែម្តង។ ខ្លួនគ្រាន់តែជួយចុះឈ្មោះប្រជាពលរដ្ឋឱ្យឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] សុខុម ប៉ុណ្ណោះ ហើយការជួយនេះខ្លួនក៏មិនទទួលបានលុយថ្លៃឈ្នួលអ្វីទេ។ ម្យ៉ាងទៀតខ្លួនគ្រាន់តែទៅស៊ើបការតាមការបញ្ជារបស់លោកអនុភូមិឈ្មោះ [redacted] វណ្ណា ភេទប្រុស និងឈ្មោះ [redacted] លាភ ភេទស្រី ដែលបានប្រើខ្លួនឱ្យទៅមើលក្រែងគេយកលុយពីប្រជាពលរដ្ឋច្រើនពេក។ ប្រជាពលរដ្ឋដែលទៅចុះឈ្មោះមានមកពីភូមិជប់រំដេង និងភូមិសែនជ័យ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] សុខុម បានឆ្លើយថា៖ ខ្លួនពិតជាបានចុះឈ្មោះប្រជាពលរដ្ឋពិតមែន។ ខ្លួនក៏បានចុះឈ្មោះទិញដីឡូត៍នឹងគេដែរ។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ឈ្មោះ [redacted] វុទ្ធី បានពឹងឱ្យខ្លួន និងឈ្មោះ [redacted] ណាត ជួយចុះឈ្មោះប្រជាពលរដ្ឋដែលស្ម័គ្រចិត្តទិញដីឡូត៍ឱ្យគាត់ដើម្បីគាត់យកបញ្ជីឈ្មោះទៅឱ្យឈ្មោះ គឹម វុទ្ធី ដោយគាត់បាននិយាយថាចាំគាត់សុំដីឡូត៍ឯកឧត្តមឈ្មោះ [redacted] វុទ្ធី ឱ្យពួកខ្លួនម្នាក់មួយឡូត៍បន្ថែមពីលើដីដែលពួកខ្លួនបានចុះឈ្មោះទិញ។ ក្នុងការចុះឈ្មោះនោះគឺតម្រូវឱ្យប្រជាពលរដ្ឋបង់លុយក្នុងម្នាក់ចំនួន ៥០ ០០០ (ប្រាំម៉ឺន) រៀល ដើម្បីយកឱ្យឈ្មោះ [redacted] វុទ្ធី យកទៅរត់ការធ្វើប្លង់ផ្ទេរសិទ្ធិកាន់កាប់។ ក្នុងថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០២០ ខ្លួនចុះឈ្មោះប្រជាពលរដ្ឋបានចំនួន ១៩ គ្រួសារបានលុយចំនួន ៦៥០ ០០០ (ហុកសិបប្រាំម៉ឺន) រៀល ហើយខ្លួនក៏បានផ្ញើលុយនេះទៅឱ្យឈ្មោះ [redacted] វុទ្ធី ក្នុងថ្ងៃនោះតែម្តង បន្ទាប់ពីខ្លួនបានផ្ញើលុយទៅឱ្យឈ្មោះ [redacted] វុទ្ធី រួចហើយ ស្រាប់តែសមត្ថកិច្ចបានចុះមកហាមឃាត់មិនឱ្យពួកខ្លួនចុះតទៅទៀត ហើយពួកខ្លួនក៏បានបញ្ឈប់សកម្មភាពនេះជារៀងរហូតលុះដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ ស្រាប់តែសមត្ថកិច្ចបានហៅពួកខ្លួនមកបំភ្លឺឡើងវិញហើយក៏បានឃាត់ខ្លួនពួកខ្លួនតែម្តង។ ប្រជាពលរដ្ឋដែលទៅចុះឈ្មោះមានមកពីភូមិជប់រំដេង ចំណែកសែនជ័យមិនបានដឹងទេ។

- សាក្សីឈ្មោះ [redacted] នាង បានឆ្លើយបញ្ជាក់ថា៖ កាលពីថ្ងៃខែមិនចាំ ឆ្នាំ២០២០ ឈ្មោះ [redacted] ចេង បានតេមកប្រាប់ខ្លួនថាមានឯកឧត្តមម្នាក់មិនស្គាល់ឈ្មោះបានវាស់វែងដីពុះជាដីឡូត៍ ដើម្បីលក់ឱ្យប្រជាពលរដ្ឋ ហើយសួរខ្លួនថាត្រូវការទិញដីនោះ ឬអត់ បើត្រូវការទិញមកចុះឈ្មោះនៅផ្ទះរបស់គាត់ ដោយមានឈ្មោះ [redacted] សុខុម ជាអ្នកចុះឈ្មោះ។ ហើយខ្លួនក៏បានទៅចុះឈ្មោះទិញដីនឹងគេនៅផ្ទះរបស់ឈ្មោះ [redacted] ដោយមានឈ្មោះ [redacted] សុខុម ជាអ្នកចុះឈ្មោះ ចំណែកឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] ណាត ខ្លួនមិនបានឃើញនោះទេ។ ក្នុងការចុះឈ្មោះទិញដីនោះ គឺតម្រូវឱ្យប្រជាពលរដ្ឋបង់លុយក្នុងម្នាក់ចំនួន ៥០ ០០០ (ប្រាំម៉ឺន) រៀល ប៉ុន្តែខ្លួនមិនទាន់បានបង់នោះទេ ព្រោះពុំទាន់មានលុយ ហើយខ្លួនចាំទៅមើលទីតាំងដីនោះសិន។ បន្ទាប់ពីចុះឈ្មោះពេលល្ងាចរួចហើយ លុះព្រឹកស្អែកខ្លួនក៏បានជិះម៉ូតូទៅមើលទីតាំងដី ដោយមានប្រជាពលរដ្ឋផ្សេងៗទៀតទៅមើលផងដែរ ប៉ុន្តែជិះម៉ូតូរៀងៗខ្លួន ពេលទៅដល់មានភ្នាក់ងារគេនាំជិះគោយន្តបន្តទៅទីតាំងដីទៀត ពេលជិះបានប្រហែល ១គីឡូម៉ែត្រ មានប្រជាពលរដ្ឋដែលរស់នៅតំបន់នោះបានសួរនាំពួកខ្លួនថាជិះគោយន្តទៅណា ហើយពួកខ្លួនក៏បានប្រាប់ថាទៅមើលទីតាំងដីឡូត៍ ពេលនោះពួកគេក៏បាននិយាយប្រាប់ពួកខ្លួនថាដីតំបន់នោះគឺជាដីរបស់សហគមន៍ មិនមែនដីរបស់បុគ្គលឯកជននោះទេ ឮដូចនេះពួកខ្លួនក៏បាននាំគ្នាជិះគោយន្តត្រឡប់មកវិញ ហើយជិះម៉ូតូទៅផ្ទះតែម្តង ដោយមិនបានទៅដល់ទីតាំងដីនោះទេ។ ក្រៅពីនេះខ្លួនមិនបានដឹងអ្វីទៀតទេ។ ក្នុងថ្ងៃដែលខ្លួនទៅចុះឈ្មោះនៅផ្ទះរបស់ឈ្មោះចេង ដោយមានឈ្មោះ [redacted] សុខុម ជាអ្នកចុះឈ្មោះនោះ គឺមានប្រជាពលរដ្ឋទៅចុះឈ្មោះប្រហែលប្រាំបួនឬដប់នាក់ដែរ ហើយនៅថ្ងៃបន្តបន្ទាប់ក៏មានប្រជាពលរដ្ឋទៅចុះឈ្មោះជាហូរហែរទៀតដែរ។

-សាក្សីឈ្មោះ [redacted] វណ្ណា បានឆ្លើយបញ្ជាក់ថា៖ ខ្លួនជាអនុភូមិជប់រំដេង។ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ខ្លួនបានដំណឹងពីប្រជាពលរដ្ឋឈ្មោះ [redacted] នាង ថាមានឈ្មោះ [redacted] សុខុម, ឈ្មោះ [redacted] ណាត និងឈ្មោះ [redacted] វុទ្ធី បានហៅប្រជាពលរដ្ឋឱ្យចុះឈ្មោះទិញដីឡូត៍ ហើយឈ្មោះ [redacted] នាង បានប្រាប់ខ្លួនថាគាត់បានទៅមើលដីនោះរួចហើយ ប៉ុន្តែដីនោះគឺជាដីសហគមន៍ មិនមែនជាដីរបស់បុគ្គលឯកជននោះទេឮដូចនេះខ្លួនបានប្រើបណ្តាញឈ្មោះ [redacted] ផន ឱ្យទៅស៊ើបមើលថាតើមានការប្រមូលប្រជាពលរដ្ឋ



Scanned with CamScanner

ឱ្យចុះឈ្មោះទិញដីឡូត៍មែន ឬអត់ និងឱ្យឈ្មោះ [redacted] ផន ទៅចុះឈ្មោះនឹងគេដើម្បីបានភស្តុតាង ដោយខ្លួនបានឱ្យលុយទៅគាត់ចំនួន ៥០ ០០០ (ប្រាំម៉ឺន) រៀល ដើម្បីចុះឈ្មោះ។ បន្ទាប់ពីឈ្មោះ [redacted] ផន ចុះឈ្មោះរួចហើយ ក៏ទទួលបានវិក័យប័ត្រលេខ ៧០ ហើយគាត់បានមកប្រាប់ខ្លួនវិញថា [redacted] សុខុម, ឈ្មោះ [redacted] ណាត និងឈ្មោះ [redacted] វុទ្ធី ពិតជាបានចុះឈ្មោះប្រជាពលរដ្ឋយកទៅទិញដីឡូត៍ប្រាកដមែន ដោយមានប្រជាពលរដ្ឋជាច្រើនទៅចុះឈ្មោះ។ បន្ទាប់ពីបានភស្តុតាងច្បាស់ហើយខ្លួនក៏បានរាយការណ៍ទៅប៉ុស្តិ៍ ហើយខាងប៉ុស្តិ៍បានរាយការណ៍បន្តទៅអធិការ ហើយអធិការបានរាយការណ៍បន្តទៅអភិបាលស្រុក។ ហើយខាងអធិការក៏បានបញ្ជាឱ្យខាងប៉ុស្តិ៍ហៅឈ្មោះ [redacted] សុខុម ឈ្មោះ [redacted] ណាត និងឈ្មោះ [redacted] វុទ្ធី មកធ្វើកិច្ចសន្យាឱ្យឈប់ធ្វើសកម្មភាពតទៅទៀត។ បន្ទាប់ពីបានណែនាំ និងឱ្យធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាពរួចហើយ ខាងប៉ុស្តិ៍ក៏បានឱ្យអ្នកទាំងបីត្រឡប់ទៅផ្ទះ និងឱ្យសងលុយទៅម្ចាស់គេវិញ។ ខ្លួនបានដឹងថាក្រៅពីចុះឈ្មោះប្រជាពលរដ្ឋនៅក្នុងភូមិដប់រំដេង ពួកអ្នកទាំងបីក៏បានទៅចុះឈ្មោះប្រជាពលរដ្ឋនៅភូមិសែនជ័យផងដែរ។ បន្ទាប់ពីខាងប៉ុស្តិ៍ហៅទៅធ្វើកិច្ចសន្យារួចហើយ អ្នកទាំងបីនៅតែបន្តធ្វើសកម្មភាពចុះឈ្មោះប្រជាពលរដ្ឋយកទៅទិញដីឡូត៍ដដែល ប៉ុន្តែពេលនោះខ្លួនមិនបានរាយការណ៍ទៀតទេ ហើយក៏មិនបានដឹងថាអ្នកណាជាអ្នករាយការណ៍ដែរ ពេលនោះខាងប៉ុស្តិ៍បានតេមកខ្លួនឱ្យហៅអ្នកទាំងបីទៅបំភ្លឺម្តងទៀត ដោយខាងប៉ុស្តិ៍ប្រាប់ថាបំភ្លឺមិនទាន់គ្រប់គ្រាន់ ប៉ុន្តែខ្លួនបានឱ្យលេខទូរស័ព្ទរបស់អ្នកទាំងបីទៅខាងប៉ុស្តិ៍ដើម្បីទាក់ទងទៅពួកគាត់ដោយខ្លួនឯង ពេលនោះខាងប៉ុស្តិ៍ក៏បានទាក់ទងទៅពួកអ្នកទាំងបីឱ្យទៅបំភ្លឺម្តងទៀត ពេលពួកគាត់ទៅក៏បានឃាត់ខ្លួនយកមកតុលាការតែម្តង។ ឈ្មោះ [redacted] សុខុម ឈ្មោះ [redacted] ណាត និងឈ្មោះ [redacted] វុទ្ធី បានប្រាប់ថាឈ្មោះ [redacted] វុទ្ធី ជាឯកឧត្តម គឺជាមេរបស់ពួកគាត់ ប៉ុន្តែខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] វុទ្ធី នេះទេ។

-សាក្សីឈ្មោះ [redacted] ចាន់ធី បានឆ្លើយបញ្ជាក់ថា៖ ដំបូងឡើយឈ្មោះ [redacted] សុខុម ហៅតាបឿ បានមកចុះឈ្មោះខ្លួន ដើម្បីចែកបង្កាន់ដៃលេខរៀងក្បាលដីនៅឧត្តរមានជ័យដោយគាត់បាននិយាយថាមានឯកឧត្តមម្នាក់គេមានដីច្រើននៅខេត្តឧត្តរមានជ័យចង់ចែកដីឲ្យប្រជាពលរដ្ឋណាក្រីក្រ ដោយក្នុងមួយគ្រួសារគេចែកដីឲ្យ៥០ម×៤០០ម ក្នុងមួយឡូតិ៍ ប៉ុន្តែគេមានល័ក្ខខណ្ឌតំរូវក្នុង១ឡូតិ៍ សុំ១គ្រួសារនូវទឹកប្រាក់ចំនួន ៥០០០០ (ប្រាំម៉ឺន)រៀល នេះជាដំណាក់កាលទី១ ដើម្បីយកទៅរត់ការឯកសារដី ពេលលឺគាត់និយាយបែបនេះរូបខ្លួនផ្ទាល់ក៏បានឲ្យគាត់ចុះឈ្មោះ នឹងគេដែរ ដោយខ្លួនបានយកដីចំនួន២ឡូតិ៍ ហើយបានបង់ប្រាក់ឲ្យឈ្មោះ [redacted] សុខុម ចំនួន ១០០០០០ (ដប់ម៉ឺន)រៀល ហើយគាត់ថាលុយនេះយកទៅរត់ការឯកសារដីឲ្យ បន្ទាប់ពីខ្លួនបង់លុយឲ្យគាត់រួចស្អែកឡើងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ពួកខ្លួនដែលមានឈ្មោះគេចែកដីឲ្យបាននាំគ្នាជិះ ម៉ូតូ៧គ្រឿង មនុស្ស ១៥នាក់ ស្រី៨នាក់ និងប្រុស ៧នាក់ ដើម្បីទៅមើលទីតាំងដីដែលគេចែកឲ្យនោះ លុះទៅដល់មាត់ផ្លូវចូលពួកខ្លួនបានឡើងជិះគោយន្តគេ ដោយក្នុងម្នាក់ៗគេយក១០០០០(មួយម៉ឺន)រៀល ប៉ុន្តែតថ្លៃបានសល់ ៥០០០(ប្រាំពាន់)រៀល។

-សាក្សីឈ្មោះ [redacted] សាញ់ បានឆ្លើយបញ្ជាក់ថា៖ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ខ្លួនបានសួរប្រជាពលរដ្ឋតៗគ្នាមានឯកឧត្តមចែកដីឡូតិ៍នៅភូមិរំចេក ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ តែមិនដឹងប៉ុន្មានឡូតិ៍ ហើយក៏មិនដឹងប៉ុន្មានហិចតាដែលឮដូចនោះហើយខ្លួនក៏ទៅចុះឈ្មោះ នឹងគេ ដោយឈ្មោះ [redacted] សុខុម កំពុងតែស្រង់ឈ្មោះប្រជាពលរដ្ឋ ប៉ុន្តែមិនដឹងគាត់ស្រង់ឈ្មោះបានប៉ុន្មាននាក់ទេ ពេលនោះខ្លួនក៏មកដល់ផ្ទះរបស់ឈ្មោះ ចេង ខ្លួនក៏ចុះឈ្មោះ បានលេខរៀងឡូតិ៍ទី០៦៨ ចំនួន១ប្លង់ ហើយគាត់

បានទារលុយខ្លួនចំនួន៥ម៉ឺនរៀល មុន សម្រាប់ការរត់ឯកសារ តែខ្លួនមិនមានលុយទេ ហើយឈ្មោះ [redacted] សុខុម បានហែកក្រដាសបង្កាន់ដៃឲ្យខ្លួន ហើយគាត់ក៏មិនបានទារលុយខ្លួនទៀត គាត់ក៏និយាយជាមួយអ្នកផ្សេង ក្រោយមកទៀតខ្លួនក៏ត្រឡប់មកផ្ទះវិញហើយលុយដែលគាត់យករត់ឯកសារក៏មិនបានឲ្យគាត់ដែល។

-សាក្សីឈ្មោះ [redacted] សុគុណ បានឆ្លើយបញ្ជាក់ថា៖ ថ្ងៃទីមិនចាំខែមិថុនា ឆ្នាំ២០២០ ខ្លួននៅផ្ទះរបស់របស់ខ្លួន តែឮគេថាចែកដីជូនប្រជាពលរដ្ឋក្រីក្រ តែមិនដឹងថាអ្នកណាជាអ្នកចែកដីទេពេលនោះក៏ឃើញឈ្មោះ [redacted] សុខុម ស្រង់ឈ្មោះប្រជាពលរដ្ឋនៅតាមផ្ទះពេលមកដល់ផ្ទះខ្លួន គាត់បាននិយាយប្រាប់ខ្លួនថាមានឯកឧត្តមម្នាក់គេធ្វើការចែកដីតែខ្លួនមិនស្គាល់ឈ្មោះ ឯកឧត្តមនោះទេ ឈ្មោះ [redacted] សុខុម បានថាដីរបស់ឯកឧត្តមចំនួន ១០០០ហិកតា ហើយចែកជូនប្រជាពលរដ្ឋចំនួន១០០គ្រួសារ ក្នុង១គ្រួសារទទួលបានដីទំហំ ២ហិកតា ត្រូវបង់លុយឲ្យគាត់មុនចំនួន ៥ម៉ឺនរៀលសំរាប់រត់ឯកសារ ដោយមួយប្លង់យកលុយចំនួន៥ម៉ឺនរៀល ចំណែកចំនួន ៣០០$ គឺឈ្មោះ [redacted] សុខុម គាត់ប្រាប់ខ្លួនថាចាំរត់ឯកសាររួចចាំយកលុយចំនួន ៣០០$ ដោយបញ្ជាក់ថាលុយនេះទុកសំរាប់ជួសជុលធ្វើផ្លូវខ្លួនឮចឹងក៏បានចុះឈ្មោះភ្លាមៗថាយកដីចំនួន ២ប្លង់ ពេលនោះឈ្មោះ [redacted] សុខុម បានទាលុយថ្លៃសំរាប់រត់ឯកសារចំនួន ១០ម៉ឺន តែខ្លួនមិនទាន់មានលុយឲ្យទេ តែគាត់បានឲ្យខ្លួនជំពាក់សិនចាំបើកលុយឲ្យគាត់ទៅ។ ក្រោយមកទៀតទើបខ្លួនបានដឹងថាឈ្មោះ [redacted] សុខុម ថាសមត្ថកិច្ចបាននាំខ្លួនទៅសួរនាំ ហើយខ្លួនត្រឡប់មកវិញដោយមិនបានឲ្យលុយគាត់ទេ។

-សាក្សីឈ្មោះ [redacted] ចេង បានឆ្លើយបញ្ជាក់ថា៖ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ឈ្មោះ[redacted] សុខុម បានអញ្ជើញទៅផ្ទះរបស់ខ្លួននៅភូមិជប់រំដេង ដើម្បីចុះឈ្មោះចែកដីឲ្យ ឈ្មោះ [redacted] សុខុម គាត់បានមកផ្ទះខ្លួន រួចគាត់និយាយថាមានឯកឧត្តមគេមានដីច្រើនចង់ចែកដីឲ្យប្រជាពលរដ្ឋណាក្រីក្រនៅភូមិជប់រំដេង ហើយឈ្មោះ [redacted] សុខុម បានសុំប្រាក់ចំនួន ៥ម៉ឺនរៀល ថ្លៃរត់ឯកសារដីឲ្យ ដោយចែកដីឲ្យមានទំហំក្បាលដី ៥០មx៤០០ម ក្នុង១គ្រួសារ ក្រោយមកលឺថា ប៉ូលីសប៉ុស្តិ៍នគរបាលរដ្ឋបាលកន្ទួតហៅគាត់សាកសួរឲ្យបញ្ឈប់សកម្មភាពសិន ចាប់ពីពេលនេះមកខ្លួនមិនបានដឹងរឿងអ្វីទៀតទេ គ្រាន់តែដឹងថាឲ្យខ្លួហចាំពីរទៅបីខែទៀតទើបដឹងពត៌មាន។ ដីដែលថាគេចែកឲ្យមានទីតាំងស្ថិតនៅខេត្តឧត្តរមានជ័យ បន្ទាប់មកទៀតឈ្មោះ [redacted] សុខុម នេះបាននិយាយថាបើកាលណាគាត់រត់ការឯកសារដីរួចហើយ មានប្លង់កាន់កាប់ដីធ្លីត្រឹមត្រូវ គាត់សុំក្នុង១គ្រួសារចំនួន ៣០០$ សំរាប់យកទៅធ្វើផ្លូវថ្នល់ពីផ្លូវជាតិឆ្ពោះទៅកាន់ទីតាំងដីដែលចែកឲ្យ ក្រៅពីនេះឈ្មោះ ហង្ស សុខុម ពុំមានយកថ្លៃសេវាអ្វីទៀតទេ។

- **សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ** ៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ និងការពិនិត្យឯកសារដែលមាននៅក្នុងសំណុំរឿង ឃើញថាមានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ[redacted] វុទ្ធី , ឈ្មោះ[redacted]ណាត , ឈ្មោះ [redacted] សុខុម និងឈ្មោះ[redacted]វុទ្ធី ឬ[redacted] វុទ្ធ ពីបទ ឆបោក ប្រាកដមែន។ ដូច្នេះតំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ: ១៧៦៧ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ទុកជាបានការដដែល។

- លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វុទ្ធី , [redacted] ណាត , [redacted] សុខុម បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនពុំបានប្រព្រឹត្តិដូចការចោទប្រកាន់នោះទេ ដោយពុំមានជាតុផ្សំបទល្មើសនោះទេ។ បើពិនិត្យជាតុអត្តនោម័តកូនក្តីខ្លួនពុំបានទៅគៀងគរ ឬដើរប្រមូលលុយពីជនរងគ្រោះនោះទេ គឺជនរងគ្រោះស្ម័គ្រចិត្តយកលុយមកឲ្យកូនក្តីខ្លួន ដើម្បីទទួលបានដីមករស់នៅ ហើយឮសនកម្មក៏ពុំមានដែល ដោយហេតុថាកូនក្តីខ្លួនបានប្រគល់ប្រាក់ឲ្យទៅជនរងគ្រោះវិញអស់ហើយ សកម្មភាពរបស់



Scanned with CamScanner

កូនក្តីខ្លួនមិនមែនជាបទល្មើសទេ ព្រោះកូនក្តីខ្លួនបានជួយរកដីឲ្យប្រជាពលរដ្ឋរស់នៅ ដែលដីនោះជារបស់រដ្ឋគ្រប់គ្រង ហើយក៏ពុំមានជនរងគ្រោះណាម្នាក់ប្តឹងកូនក្តីខ្លួនដែល អ្នកដែលប្តឹងកូនក្តីខ្លួន គឺភាគីរដ្ឋ ហើយបានដកពាក្យបណ្តឹងផងដែរ។ ដូចនេះស្នើសុំឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់។

- លោក [redacted]ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ឬ[redacted] វុទ្ធ បានធ្វើសេចក្តីសន្និដ្ឋានថា ពុំមានភស្តុតាងណាមួយបញ្ជាក់ថាកូនក្តីខ្លួនឈ្មោះ គឹម វុទ្ធី បានប្រព្រឹត្តបទល្មើសនោះទេ ដូចនេះស្នើសុំឲ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទប្រកាន់។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ខ្លួនស្នើសុំឲ្យតុលាការមេត្តាជួយសម្រាលទោសដល់ខ្លួនផង ព្រោះខ្លួនបានដឹងកំហុសហើយ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ណាត ខ្លួនស្នើសុំឲ្យតុលាការមេត្តាជួយសម្រាលទោសដល់ខ្លួនផង ព្រោះខ្លួនបានដឹងកំហុសហើយ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខុម ខ្លួនស្នើសុំឲ្យតុលាការមេត្តាជួយសម្រាលទោសដល់ខ្លួនផង ព្រោះខ្លួនបានដឹងកំហុសហើយ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុវុទ្ធី , [redacted] ណាត , [redacted] សុខុម

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី

-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល និងពិនិត្យភស្តុតាងនាពេលសវនាការឃើញថា៖

១- តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៨៩៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ៨៩៩៥ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ដែលបានបញ្ជូនជនជាប់ចោទ៖

ក. ឈ្មោះ [redacted] **វុទ្ធី** ភេទប្រុស អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ។

ខ. ឈ្មោះ [redacted] **ណាត** ភេទប្រុស អាយុ ៥៧ឆ្នាំ ជនជាតិខ្មែរ ។

គ. ឈ្មោះ [redacted] **សុខុម** ភេទប្រុស អាយុ ៦៤ឆ្នាំ ជនជាតិខ្មែរ។

ឃ. ឈ្មោះ [redacted] ឬ[redacted] **វុទ្ធ** ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ។

មកជំនុំជម្រះពីបទៈ **ឆបោក** ប្រព្រឹត្តនៅភូមិសែនជ័យ និងភូមិជប់រំដេង ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២- <u>កស្តុតាងដាក់បន្ទុកមាន៖</u>

-តាមរបាយការណ៍សំយោគលេខៈ ០៧ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលស្រុកស្វាយលើ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានសន្និដ្ឋានបញ្ជាក់ថាឈ្មោះ [redacted] វុទ្ធី , ឈ្មោះ [redacted] ណាត , ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] វុទ្ធី ឬ[redacted] វុទ្ធ ពិតជាបានប្រព្រឹត្តអំពើ **ឆបោក**



Scanned with CamScanner

ប្រព្រឹត្តនៅភូមិសែនជ័យ និងភូមិដប់រំដេង ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ប្រាកដមែន។

-ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានឆ្លើយថា កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ឈ្មោះ [redacted] ស៊ីនួន ដែលជាក្មេីរបស់ខ្លួនបានមកនិយាយប្រាប់ខ្លួនថាគាត់មានដីចំនួន១០០០ (មួយពាន់) ហិចតា ហើយ គាត់ចង់ធ្វើប្លង់កាន់កាប់ស្របច្បាប់រួចហើយលក់ចេញ ប៉ុន្តែគាត់មិនដឹងរត់ការតាមអ្នកណាពេលនោះខ្លួនក៏បានណែនាំឱ្យទៅពឹងឯកឧត្តមឈ្មោះ [redacted] វុទ្ធី ជាទាហានដើម្បីជួយរត់ការធ្វើប្លង់ឱ្យ។ ពេលដែលបានជួបនិយាយជាមួយឯកឧត្តម [redacted] វុទ្ធី ពេលនោះឈ្មោះ [redacted] វុទ្ធ បានសុំចំណែកដីពីឈ្មោះ [redacted] ស៊ីនួន ចំនួនពាក់កណ្ដាលជាថ្នូនឹងការរត់ការធ្វើប្លង់កាន់កាប់ ពេលនោះឈ្មោះ [redacted] ស៊ីនួន ក៏បានយល់ព្រមឱ្យដីទៅឈ្មោះ [redacted] វុទ្ធី ក្បាលចំនួន ៦០០ម៉ែត្រ បណ្ដោយមិនដឹងប៉ុន្មាននោះទេ។ បន្ទាប់មកឈ្មោះ [redacted] ស៊ីនួន ឈ្មោះ [redacted] វុទ្ធី និងខ្លួនបានពិភាក្សាគ្នាថាបើលក់ទាំងអស់គ្មានអ្នកណាមានលុយទិញទេ ប៉ុន្តែបើពុះជាដីឡូត៍លក់ទើបគេមានលុយទិញ។ ក្រោយពីពិភាក្សាគ្នារួចបានប្រហែលជា ២ ឬ៣ថ្ងៃ ស្រាប់តែឈ្មោះ [redacted] ស៊ីនួន បានស្លាប់បាត់ទៅ។ បន្ទាប់មកទៀតឈ្មោះ [redacted] វុទ្ធី បានឱ្យខ្លួនរៀបចំចុះឈ្មោះប្រជាពលរដ្ឋដែលស្ម័គ្រចិត្តទិញដីឡូត៍ ដែលមានទំហំ ៥០ ម៉ែត្រ គុណ ៤០០ ម៉ែត្រ ក្នុងតម្លៃ ៣០០ (បីរយ) ដុល្លារអាមេរិក ដោយការចុះឈ្មោះនោះតម្រូវឱ្យប្រជាពលរដ្ឋបង់លុយក្នុងម្នាក់ចំនួន ៥០ ០០០ (ប្រាំម៉ឺន) រៀល ដើម្បីយកលុយនេះទៅរត់ការជាមួយអាជ្ញាធរភូមិក្នុងការរៀបចំពុះជាដីឡូត៍បែងចែកឱ្យប្រជាពលរដ្ឋដែលបានចុះឈ្មោះទិញ។ លុះមកដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ខ្លួនបានយករឿងពុះដីឡូត៍លក់មកនិយាយប្រាប់ឈ្មោះ [redacted] សុខុម , ឈ្មោះ [redacted] ណាត ពេលនោះអ្នកទាំងពីរក៏បានចុះឈ្មោះទិញម្នាក់មួយឡូត៍ផងដែរ។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ខ្លួនបានពឹងឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] ណាត និងឈ្មោះ [redacted] ផល្លី ជាអ្នករស់នៅភូមិសែនជ័យឱ្យជួយចុះឈ្មោះប្រជាពលរដ្ឋពេលនោះដោយសារខ្លួនគ្មានលុយឱ្យថ្លៃឈ្នួលអ្នកទាំងបី ខ្លួនក៏បានតេទៅឈ្មោះ [redacted] វុទ្ធី ដើម្បីសុំដីឡូត៍ឱ្យអ្នកទាំងបីម្នាក់មួយឡូត៍ជាថ្លៃជួយចុះឈ្មោះប្រជាពលរដ្ឋ ហើយឈ្មោះ [redacted] វុទ្ធី ក៏យល់ព្រម។ ខ្លួនបានចុះឈ្មោះប្រជាពលរដ្ឋបានចំនួន ៧គ្រួសារ បានលុយចំនួន ៣៥ ០០០ (សាមសិបប្រាំម៉ឺន) រៀល ប៉ុន្តែមិនមែនខ្លួនសសេរដោយខ្លួនឯងទេ គឺឈ្មោះ [redacted] ផល្លី ជាអ្នកជួយសសេរឱ្យ ហើយលុយគឺឈ្មោះ [redacted] ផល្លី ជាអ្នកកាន់ចំណែកឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] ណាត ខ្លួនមិនបានដឹងថាពួកគេចុះឈ្មោះបានម្នាក់ប៉ុន្មាននោះទេ។ ពេលកំពុងតែចុះឈ្មោះស្រាប់តែសមត្ថកិច្ចបានចុះហាមឃាត់មិនឱ្យចុះឈ្មោះតទៅទៀតខ្លាចចុះបោកគេ ហើយពួកខ្លួនក៏ឈប់ធ្វើសកម្មភាពនេះតទៅទៀត រហូតមកដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០២០ ស្រាប់តែសមត្ថកិច្ចកោះហៅពួកខ្លួនទៅសាកសួរអធិការដ្ឋានស្រុកស្វាយលើ ហើយក៏បានឃាត់ខ្លួនពួកខ្លួនតែម្ដង។ ក្នុងការធ្វើសកម្មភាពចុះឈ្មោះប្រជាពលរដ្ឋនេះ ខ្លួនទទួលបានដីឡូត៍ចំនួនមួយឡូត៍ដូចពួកគេដែរ។ ប្រជាពលរដ្ឋដែលទៅចុះឈ្មោះមានមកពីភូមិដប់រំដេង និងភូមិសែនជ័យ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប។

ចម្លើយរបស់ជនជាប់ចោទអាចឲ្យជឿបាន ពីព្រោះចម្លើយទាំងអស់នេះស៊ីសង្វាក់គ្នាតាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ , ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួររួមនឹង និងវត្ថុចាប់យកជាក់ស្ដែង ព្រមទាំងឯកសារជាភស្តុតាងមានលក្ខណៈស៊ីសង្វាក់គ្នាបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ពិតជាបានប្រព្រឹត្តអំពើ ឆបោក កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ប្រាកដមែន។



Scanned with CamScanner

-ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ណាត បានឆ្លើយថា កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ខ្លួនបានទៅតភ្លើងនៅវត្តជប់រំដេង ហើយក៏បានជួបឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] សុខុម ពេលនោះអ្នកទាំងពីរនាក់បាននិយាយប្រាប់ខ្លួនថាឯកឧត្តមឈ្មោះ [redacted] វុទ្ធី មានដីចំនួន ១០០០ (មួយពាន់) ហិចតា ស្ថិតនៅភូមិរំចេក១ ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ហើយឯកឧត្តមឈ្មោះ គឹម វុទ្ធ ចង់អភិវឌ្ឍន៍ដីតំបន់នោះ ដោយឱ្យពួកឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] សុខុម ជាអ្នកដើរចុះឈ្មោះប្រជាពលរដ្ឋណាដែលចង់ទៅរស់នៅលើដីក្នុងតំបន់នោះ ដោយការចុះឈ្មោះត្រូវបង់លុយចំនួន ៥០ ០០០ (ប្រាំម៉ឺន) រៀល ជាសោហ៊ុយសម្រាប់គេនាំទៅមើលដី។ ពេលនោះខ្លួនក៏បានឱ្យឈ្មោះ [redacted] សុខុម ចុះឈ្មោះខ្លួនមួយនឹងគេដែរ ប៉ុន្តែខ្លួនមិនទាន់បានបង់លុយថ្លៃធ្វើសោហ៊ុយទៅមើលដីចំនួន ៥០០០០ (ប្រាំម៉ឺន) រៀល នោះទេ លុះដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ៧ ព្រឹក ខ្លួនបានទៅផឹកការហ្វេនៅផ្ទះឈ្មោះ [redacted] រឿន ស្រាប់តែបានជួបឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] សុខុម កំពុងចុះឈ្មោះប្រជាពលរដ្ឋដែលចង់ទៅមើលដី ដើម្បីទិញពេលនោះអ្នកទាំងពីរក៏បានពឹងឱ្យខ្លួនជួយចុះឈ្មោះប្រជាពលរដ្ឋឱ្យពួកគេ ហើយខ្លួនក៏បានចុះឈ្មោះប្រជាពលរដ្ឋបានចំនួន ១៩ គ្រួសារ បានលុយចំនួន ១៥០ ០០០(ដប់ប្រាំម៉ឺន) រៀល ដោយអ្នកខ្លះបង់លុយតែម្តង ចំណែកអ្នកខ្លះទៀតចាំបង់នៅពេលក្រោយ។ ពេលកំពុងចុះឈ្មោះស្រាប់តែសមត្ថកិច្ចក៏បានចុះមកដល់ហាមឃាត់មិនឱ្យចុះតទៅទៀត ពេលនោះខ្លួនក៏ឈប់ហើយដើរចេញទៅជាមួយសមត្ថកិច្ចក្រុមរបស់ខ្លួន(ខ្លួនជាប្រជាការពារភូមិ)តែម្តង។ ក្រោយមកខ្លួនបានទៅមើលដី ហើយបានជួបឯកឧត្តមឈ្មោះ [redacted] វុទ្ធី ផងដែរពេលនោះគាត់ប្រាប់ថាគាត់រកលក់ដីឱ្យប្រជាពលរដ្ឋដែលចង់ទៅរស់នៅទីនោះក្នុងតម្លៃ ៣០០ (បីរយ) ដុល្លារអាមេរិក ក្នុងទំហំ ២ (ពីរ) ហិចតា ហើយចំពោះប្រជាពលរដ្ឋដែលចុះឈ្មោះទិញដីទាំងអស់មិនតម្រូវឱ្យបង់លុយភ្លាមទេ រង់ចាំឯកឧត្តម [redacted] វុទ្ធី នាំទៅមើលដីរួចសិន បើអ្នកណាចង់ទិញគាត់នឹងរត់ការផ្ទេរកម្មសិទ្ធិមកឱ្យ ប៉ុន្តែតម្រូវឱ្យបង់លុយថ្លៃរត់ការមួយចំនួនសិន នៅខ្វះលុយប៉ុន្មានចាំទទួលបានប័ណ្ណកាន់កាប់រួចហើយចាំបង់បង្គ្រប់តាមក្រោយ។ ក្រោយមកនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ សមត្ថកិច្ចខាងអធិការស្រុកស្វាយលើបានហៅខ្លួនឱ្យទៅបំភ្លឺសារជាថ្មីអំពីរឿងចុះឈ្មោះប្រជាពលរដ្ឋនោះ ពេលគេសួរនាំរួចហើយស្រាប់តែគេឃាត់ខ្លួនតែម្តង។ ខ្លួនគ្រាន់តែជួយចុះឈ្មោះប្រជាពលរដ្ឋឱ្យឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] សុខុម ប៉ុណ្ណោះ ហើយការជួយនេះខ្លួនក៏មិនទទួលបានលុយថ្លៃឈ្នួលអ្វីទេ។ ម្យ៉ាងទៀតខ្លួនគ្រាន់តែទៅស៊ើបការតាមការបញ្ជារបស់លោកអនុភូមិឈ្មោះ [redacted] វណ្ណា ភេទប្រុស និងឈ្មោះ [redacted] លាភ ភេទស្រី ដែលបានប្រើខ្លួនឱ្យទៅមើលក្រែងគេយកលុយពីប្រជាពលរដ្ឋច្រើនពេក។ ប្រជាពលរដ្ឋដែលទៅចុះឈ្មោះមានមកពីភូមិជប់រំដេង និងភូមិសែនជ័យ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប។

ចម្លើយរបស់ជនជាប់ចោទអាចឲ្យជឿបាន ពីព្រោះចម្លើយទាំងអស់នេះស៊ីសង្វាក់គ្នាតាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ , ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួររួមនឹង និងវត្ថុចាប់យកដាក់ស្តែង ព្រមទាំងឯកសារជាភស្តុតាងមានលក្ខណៈស៊ីសង្វាក់គ្នាបញ្ជាក់ថា ជនជាប់ចោទឈ្មោះ ពត ណាត ពិតជាបានប្រព្រឹត្តអំពើ ឆបោក កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ប្រាកដមែន។

-ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុខុម បានឆ្លើយថា ខ្លួនពិតជាបានចុះឈ្មោះប្រជាពលរដ្ឋពិតមែន។ ខ្លួនក៏បានចុះឈ្មោះទិញដីឡូត៍នឹងគេដែរ។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ឈ្មោះ [redacted] វុទ្ធី បានពឹងឱ្យខ្លួន និងឈ្មោះ [redacted] ណាត ជួយចុះឈ្មោះប្រជាពលរដ្ឋដែលស្ម័គ្រចិត្តទិញដីឡូត៍ឱ្យគាត់ដើម្បីគាត់យកបញ្ជីឈ្មោះទៅឱ្យឈ្មោះ [redacted] វុទ្ធី ដោយគាត់បាននិយាយថាចាំគាត់សុំដី



Scanned with CamScanner

ឡូត៍ឯកឧត្តមឈ្មោះ [redacted] វុទ្ធី ឱ្យពួកខ្លួនម្នាក់មួយឡូត៍បន្ថែមពីលើដីដែលពួកខ្លួនបានចុះឈ្មោះទិញ។ ក្នុងការចុះឈ្មោះនោះគឺតម្រូវឱ្យប្រជាពលរដ្ឋបង់លុយក្នុងម្នាក់ចំនួន ៥០ ០០០ (ប្រាំម៉ឺន) រៀល ដើម្បីយកឱ្យឈ្មោះ [redacted] វុទ្ធី យកទៅរត់ការធ្វើប្លង់ផ្ទេរសិទ្ធិកាន់កាប់។ ក្នុងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ខ្លួនចុះឈ្មោះប្រជាពលរដ្ឋបានចំនួន ១៩គ្រួសារ បានលុយចំនួន ៦៥០ ០០០ (ហុកសិបប្រាំម៉ឺន) រៀល ហើយខ្លួនក៏បានផ្ញើលុយនេះទៅឱ្យឈ្មោះ [redacted] វុទ្ធី ក្នុងថ្ងៃនោះតែម្តង បន្ទាប់ពីខ្លួនបានផ្ញើលុយទៅឱ្យឈ្មោះ [redacted] វុទ្ធី រួចហើយ ស្រាប់តែសមត្ថកិច្ចបានចុះមកហាមឃាត់មិនឱ្យពួកខ្លួនចុះតទៅទៀត ហើយពួកខ្លួនក៏បានបញ្ឈប់សកម្មភាពនេះជារៀងរហូត លុះដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ ស្រាប់តែសមត្ថកិច្ចបានហៅពួកខ្លួនមកបំភ្លឺឡើងវិញហើយក៏បានឃាត់ខ្លួនពួកខ្លួនតែម្តង។ប្រជាពលរដ្ឋដែលទៅចុះឈ្មោះមានមកពីភូមិជប់រំដេងចំណែកសែនជ័យមិនបានដឹងទេ។

ចម្លើយរបស់ជនជាប់ចោទអាចឲ្យជឿបាន ពីព្រោះចម្លើយទាំងអស់នេះស៊ីសង្វាក់គ្នាតាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ , ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ និងវត្ថុចាប់យកជាក់ស្តែង ព្រមទាំងឯកសារជាភស្តុតាងមានលក្ខណៈស៊ីសង្វាក់គ្នាបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] សុខុម ពិតជាបានប្រព្រឹត្តអំពើ ឆបោក កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ប្រាកដមែន។

- ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ឬកឹម វុទ្ធ អវត្តមានគ្រប់ដំណាក់កាល នៃនីតិវិធីពុំមានចម្លើយក្នុងសំណុំរឿង។ តែតាមអង្គហេតុអាចឲ្យជឿបានថាជនជាប់ចោទបានប្រព្រឹត្តដូចបទចោទ ហើយមានភាពស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ជនជាប់ចោទ , ចម្លើយសាក្សី ដែលចម្លើយមានភាពស៊ីសង្វាក់គ្នាទៅនឹងឯកសាររបស់មន្ត្រីនគរបាលយុត្តិជាភស្តុតាងបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ឬ[redacted] វុទ្ធ ពិតជាបានប្រព្រឹត្ត ឆបោក កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ប្រាកដមែន។

- អំពើរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ របៀបរយល្អក្នុងសង្គម ដែលច្បាប់ហាមឃាត់ ជាពិសេសបានបំពានទៅនឹងមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

- មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទៈ

ក. ឈ្មោះ [redacted]**វុទ្ធី** ភេទប្រុស អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ។

ខ. ឈ្មោះ [redacted]**ណារាត** ភេទប្រុស អាយុ ៥៧ឆ្នាំ ជនជាតិខ្មែរ ។

គ. ឈ្មោះ [redacted]**សុខុម** ភេទប្រុស អាយុ ៦៤ឆ្នាំ ជនជាតិខ្មែរ។

ឃ. ឈ្មោះ [redacted]**វុទ្ធី ឬ**[redacted] **វុទ្ធ** ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ។

ពីបទៈ **ឆបោក** ប្រព្រឹត្តនៅភូមិសែនជ័យ និងភូមិជប់រំដេង ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៣- ការប្រកាសទោស

- ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី , ឈ្មោះ [redacted] ណាត , ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] វុទ្ធី ឬ [redacted] វុទ្ធ ជានីតិជនមានបុគ្គលិកលក្ខណៈ គ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌបាន។ ជនជាប់ចោទមានសមត្ថភាពខាងធន្ទៈ ឬមានស្មារតីល្អគ្រប់គ្រាន់ដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលកើតចេញពីអំពើដែលខ្លួនបានប្រព្រឹត្ត។


Scanned with CamScanner

៤- សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ បានសុំឲ្យចៅក្រមជំនុំជម្រះ សម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] វុទ្ធី , ឈ្មោះ [redacted] ណាត , ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] ទ្ធី ឬ [redacted] វុទ្ធ ពីបទឆបោក ប្រព្រឹត្តនៅភូមិសែនជ័យ និងភូមិជប់រំដេង ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-តុលាការយល់ឃើញថាសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ មានលក្ខណៈត្រឹមត្រូវដែលគប្បីពិចារណា។

- ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី , ឈ្មោះ [redacted] ណាត និងឈ្មោះ [redacted] សុខុម ជនជាប់ចោទទាំងបីនាក់ទើបតែប្រព្រឹត្តបទល្មើសលើកដំបូង , ជនជាប់ចោទមានអាយុច្រើន និងជនជាប់ចោទមានស្មារតីភ្ញាក់រលឹកសារភាពនូវទង្វើដែលបានប្រព្រឹត្តរបស់ខ្លួន ម្យ៉ាងទៀតព្យសនកម្មកើតឡើងមានលក្ខណៈតិចតួច។

## ហេតុដូច្នេះសម្រេច

**១- ផ្តន្ទាទោស៖**

ក. ឈ្មោះ [redacted] **វុទ្ធី** ភេទប្រុស អាយុ៦៤ឆ្នាំ ជនជាតិខ្មែរដាក់ពន្ធនាគារកំណត់ **៦ (ប្រាំមួយ)ខែ**។

ខ. ឈ្មោះ [redacted] **ណាត** ភេទប្រុស អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **៦ (ប្រាំមួយ)ខែ** ។

គ. ឈ្មោះ [redacted] **សុខុម** ភេទប្រុស អាយុ ៦៤ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **៦ (ប្រាំមួយ)ខែ**។

ឃ. ឈ្មោះ [redacted] **វុទ្ធី ឬ** [redacted] **វុទ្ធ** ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **១ (មួយ) ឆ្នាំ** ។

ពីបទៈ **ឆបោក** ប្រព្រឹត្តនៅភូមិសែនជ័យ និងភូមិជប់រំដេង ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

**២-** សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វុទ្ធី , ឈ្មោះ [redacted] ណាត , ឈ្មោះ [redacted] សុខុម និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ឬ [redacted] វុទ្ធ។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃស្រុក ១១កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
សៀមរាប ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០
**ក្រឡាបញ្ជី**
[redacted]



Scanned with CamScanner